ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៤៥៦៩ អពដ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សាររំលែកមរណទុក្ខ

**សូមគោរពជូន**
**លោកជំទាវ អានី សុខអាន**

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារ និងក្នុងនាមខ្ញុំផ្ទាល់ យើងខ្ញុំទាំងអស់គ្នាមានសេចក្តីរន្ធត់ក្តុកក្តួល ក្រៀមក្រំឥតឧបមា ដោយបានទទួលដំណឹងថា **សម្តេចវិបុលបញ្ញា សុខ អាន** សមាជិករដ្ឋសភា និងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានទទួលមរណភាពកាលពីវេលាម៉ោង ១៨:៣២ នាទី ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ក្នុងជន្មាយុ ៦៦ ឆ្នាំ ដោយរោគាពាធ។

ការបាត់បង់ **សម្តេចវិបុលបញ្ញា** គឺជាការបាត់បង់នូវឥស្សរជនថ្នាក់ដឹកនាំជាតិដ៏ឆ្នើមមួយរូប ដែលបានបូជាកម្លាំងកាយ ចិត្ត ប្រាជ្ញាស្មារតី ពុះពារគ្រប់ឧបសគ្គ និងគ្រប់កាលៈទេសៈ ក្នុងការចូលរួមកសាងសុខសន្តិភាព ឯកភាពជាតិ ស្ថិរភាពនយោបាយ រហូតទទួលបានការអភិវឌ្ឍជាតិដូចសព្វថ្ងៃ និងជាការបាត់បង់ឧត្តមស្វាមី បិតា និងជីតា ដែលពោរពេញដោយព្រហ្មវិហារធម៌ និងទឹកចិត្តសណ្តោសប្រណីដ៏ថ្លៃថ្លា ចំពោះបុត្រ-ធីតា និងចៅៗជាទីស្រឡាញ់។

ស្ថិតក្នុងឱកាសដ៏សែនក្រៀមក្រំ វិយោគសោកស្តាយរកទីបំផុតគ្មាននេះ ខ្ញុំសូមចូលរួមសម្តែងនូវមរណទុក្ខ និងក្តីអាឡោះអាល័យ ជាមួយ**លោកជំទាវ** និងក្រុមគ្រួសារ និងសូមលំឱនកាយឧទ្ទិសបួងសួងសូមដួងវិញ្ញាណក្ខន្ធ **សម្តេចវិបុលបញ្ញា សុខ អាន** ឆាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូមលោកជំទាវ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិនា ឆ្នាំ២០១៧
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**